**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងរដ្ឋប្បវេណីលេខ:១៩
ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០
**សាលក្រមលេខ: ០៩(ខ)**
**ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០**

# ស ា ល ក្រ ម ប្រ ជា រា ស្រ្ត ខ្មែ រ

## សាលាដំបូងខេត្តសៀមរាប

-បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅបន្ទប់ សវនាការលេខ ក៣ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ៣:៣០នាទីរសៀល និងបានប្រកាសសាលក្រម នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ នៅសាលាដំបូងខេត្តសៀមរាប។

**ចៅក្រមជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

លើសំណុំរឿងរដ្ឋប្បវេណីលេខ: ១៩ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ដែលមាន៖

-ដើមចោទ: ឈ្មោះ [redacted] វីរៈ ភេទប្រុស អាយុ កើតឆ្នាំ១៩៨៥ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ។

ដោយមានលោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

-ចុងចម្លើយ: ឈ្មោះ [redacted] សុធាវី ភេទស្រី កើតឆ្នាំ១៩៩៣ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted]។

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

### ១-អង្គហេតុ និងចំណុចវិវាទ

១-១-ដើមចោទប្តឹងសុំឲ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

-សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] សុធាវី។

-សុំរំលស់ប្រាក់ប្រដាប់ក្តីដោយខ្លួនឯង។

១-២-ការពន្យល់ត្រួសៗពីអង្គហេតុ

ដើមចោទ បានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] សុធាវី ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០៥៥ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់មន្រ្តី

អគ្រានុកូលដ្ឋាន ចៅសង្កាត់ស្វាយដង្គំ ប៉ុន្តែចាប់តាំងពីរៀបការរហូតមកដល់បច្ចុប្បន្ន គឺមិនមានការចុះសម្រុងជាមួយគ្នានោះទេ ហើយមកដល់ពេលនេះ ដើមចោទអស់មនោសញ្ចេតនារស់នៅជាប្តីប្រពន្ធជាមួយចុងចម្លយតទៅទៀតហើយ។ នៅក្នុងអំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍នេះ ដើមចោទ និងចុងចម្លើយពុំមានកូន ពុំមានទ្រព្យសម្បត្តិ ឬបំណុលរួមនោះទេ។

១-៣-សេចក្តីថ្លែងការណ៍របស់ភាគី

មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា: សុំឲ្យតុលាការសម្រេចសេចក្តីដូចតទៅ៖

-សុំលែងលះពីចុងចម្លើយ។

-សុំឲ្យចុងចម្លើយរ៉ាប់រងប្រាក់ប្រដាប់ក្តី។

កូនក្តីខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] សុធាវី ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០៥៥ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់មន្ត្រីអគ្រានុកូលដ្ឋានចៅសង្កាត់ស្វាយដង្គំ ប៉ុន្តែចាប់ពីរៀបការរហូតមកដល់បច្ចុប្បន្ន គឺមិនមានការចុះសម្រុងជាមួយគ្នានោះទេ ហើយមកដល់ពេលនេះ កូនក្តីខ្លួនអស់មនោសញ្ចេតនារស់នៅជាប្តីប្រពន្ធជាមួយចុងចម្លើយតទៅទៀតហើយ។ នៅក្នុងអំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍នេះ កូនក្តីខ្លួន និងចុងចម្លើយពុំមានកូន ពុំមានទ្រព្រសម្បត្តរួម ឬបំណុលរួមនោះទេ។ ហេតុដូចនេះ ទើបកូនក្តីខ្លួនសូមឲ្យសាលាដំបូងខេត្តសៀមរាបចេញសាលក្រមដូចមានក្នុងទាមទារ។ នៅដើមខែសីហា ឆ្នាំ២០១៩ ដើមចោទ និងចុងចម្លើយបានឈ្លោះប្រកែងគ្នាយ៉ាងខ្លាំងពីបញ្ហាមួយចំនួននៅក្នុងគ្រួសារ ហើយចុងចម្លើយក៏បានចុះចេញពីលំនៅឋានចោលដើមចោទបន្ទាប់ពីឈ្លោះប្រកែកគ្នារួច ចាប់តាំងពីថ្ងៃនោះ រហូតមកដល់ពេលនេះចុងចម្លើយមិនបានត្រឡប់មករស់ជុំគ្នាវិញនោះទេ គឺដើមចោទនិងចុងចម្លើយរស់នៅបែកគ្នារៀងៗខ្លួន ។

ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍តបថា: ខ្លួនមិនព្រមលែងលះទេ ព្រោះខ្លួននៅស្រឡាញ់ដើមចោទខ្លាំងណាស់។ បើគាត់នៅតែរឹងរូសលែងលះ គឺខ្លួនស្នើសុំបែងចែកខុនដូ ជាពីរចំណែក និងសុំឲ្យដើមចោទប្រគល់ខ្សែករមាស ០១ខ្សែ ចិញ្ចៀនផ្កាទីន ០១វង់ និងក្រវិលពេជ្រ ០១គូរ។ ចំពោះប្រាក់ប្រដាប់ក្តី គឺសុំឲ្យដើមចោទជាអ្នកបង់។ ខ្លួនសុំដាក់ពាក្យបណ្តឹងតបដូចតទៅ៖

១.ច្រានចោលការទាមទារលែងលះក្នុងពាក្យបណ្តឹងលែងលះ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ របស់ចុងបណ្តឹងតប។

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងបណ្តឹងតប។



Scanned with CamScanner

ខ្លួន និងចុងបណ្តឹងតបបានស្រឡាញ់គ្នាជាសង្សារនៅចុងឆ្នាំ២០១១។ នៅឆ្នាំ ២០១៣ ចុងបណ្តឹងតបក៏បានអាហារូបករណ៍បន្តការសិក្សានៅប្រទេសអូស្ត្រាលី រយៈពេល ០១ឆ្នាំកន្លះ។ នៅខែវិច្ឆិកា ឆ្នាំ២០១៤ ចុងបណ្តឹងតបបានធានាខ្លួនឲ្យទៅលេងគាត់នៅប្រទេសអូស្ត្រាលី រយៈពេលជិត០១ខែ។ នៅឆ្នាំ២០១៥ ចុងបណ្តឹងតបបានបញ្ចប់ការសិក្សា ហើយត្រឡប់មកកម្ពុជាវិញ។ ក្រោយការវិលត្រឡប់មកកម្ពុជាវិញ ទំនាក់ទំនងយើងទាំងពីរកាន់តែល្អប្រសើរ ហើយពួកយើងក៏សម្រេចចិត្តរស់នៅជាអនីតិសង្វាសជាមួយគ្នា។ ឈានចូលឆ្នាំ២០១៦ យើងទាំងពីរនាក់បានទៅជួបគ្រួសារទាំងសងខងដើម្បីណែនាំពីគូរអនាគត និងសុំការអនុញ្ញាតឲ្យមានការយល់ព្រមពីមេបាទាំងសងខាង។ ក្នុងអំឡុងពេលនោះដែរពួកយើងសម្រេចចិត្តទិញខុនដូពីក្រុមហ៊ុនយូខេខុនដូ (UK Condo) ជាន់ទី១៦ ទំហំ ៥១ម៉ែត្រការ៉េ ស្ថិតនៅលើផ្លូវ៣១៣ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ចុងបណ្តឹងតបជាអ្នកយកលុយទៅកក់ថ្លៃខុនដូ ខ្លួនមិនបានទៅជាមួយទេ។ ការទិញបន្ទប់ខុនដូនេះធ្វើឡើងជាទម្រង់បង់រំលោះរយៈពេល ០៣ឆ្នាំជាង។ ការទិញខុនដូនេះធ្វើឡើងដោយដាក់ឈ្មោះចុងបណ្តឹងតបជាអ្នកឈរឈ្មោះបង់ប្រាក់កក់ ព្រោះខ្លួន និងបណ្តឹងតបមិនទាន់ចុះសំបុត្រអាពាហ៍ពិពាហ៍នៅឡើយ។ ហើយក្រោយពីចុះសំបុត្រអាពាហ៍ពិពាហ៍នឹងគ្នានៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ ក៏ក្រុមហ៊ុននៅតែមិនទាន់ផ្ទេរជាកម្មសិទ្ធិរួមឲ្យ ព្រោះអាគារខុនដូមិនទាន់សាងសង់រួចរាល់ និងបច្ចុប្បន្ននេះចុងបណ្តឹងតបជាអ្នកចាត់ចែងទាំងអស់។ ខ្លួនសូមបញ្ជាក់ថា ជារៀងរាល់ពេលដែលបណ្តឹងតបយកលុយទៅបង់បន្ទប់ខុនដូ គាត់តែងតែថតរូបសំណង់ខុនដូផ្ញើឲ្យខ្លួនមើលដើម្បីតាមដានការវិវឌ្ឍន៍របស់សំណង់ខុនដូ។នៅក្នុងខែមិថុនា ឆ្នាំ២០១៩ ចុងចម្លើយមានបញ្ហាសុខភាពកើតឡើងដោយគ្រូពេទ្យបានពិនិត្យឃើញថា គាត់មានបញ្ហារលាកផ្លូវនោម។ ក្នុងអំឡុងពេលនោះដើមចោទពុំបានជូនចុងចម្លើយទៅពេទ្យព្យាបាលទេ ដោយចុងចម្លើយត្រូវមកខ្លួនឯងដើម្បីព្យាបាលជំងឺដោយការប្រើប្រាស់ថ្នាំលេប និងព្យួរសេរ៉ូមជារៀងរាល់កន្លះថ្ងៃសម្រាប់រយៈពេលពេញមួយសប្តាហ៍។ ការព្យាបាលជាសះស្បើយមិនដល់មួយខែផងស្រាប់តែកើតឡើងម្តងទៀត ចុងចម្លើយក៏បន្តការព្យាបាល ប៉ុន្តែដើមចោទមិនបានមើលថែទាំចុងចម្លើយទេ។ នៅដើមខែសីហា ឆ្នា២០១៩ ភាគីទាំងពីរបានឈ្លោះប្រកែកគ្នាលើរឿងហិរញ្ញវត្ថុ និងរឿងការរួមភេទ ហើយចុងក្រោយ ដើមចោទបានចាកចេញពីលំនៅសង្វាស និងបានដាក់បណ្តឹងលែងលះពីចុងចម្លើយទៅសាលាដំបូងខេត្តសៀមរាប។

មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានថ្លែងការណ៍តបថា៖ ខុនដូជាទ្រព្យសម្បត្តិដោយឡែក ព្រោះដើមចោទបានបង់តាំងពីឆ្នាំ២០១៦ រហូតមក ដល់ចុះសំបុត្រអាពាហ៍ពិពាហ៍ហើយបានបង់ផ្តាច់ ហើយដើមចោទបានខ្ចីលុយម្តាយខ្លួនមកបង់ផ្តាច់។

ចំពោះការលើកឡើងរបស់ចុងចម្លើយថា ខ្សែករមាស ០១ខ្សែ ចិញ្ចៀន ០១វង់ និងក្រវិល ០១គូរ ដែលចុងចម្លើយលើកឡើង សុំបដិសេធចោលទាំងស្រុង ដូចនេះស្នើឲ្យចុងចម្លើយដាក់ភស្តុតាង។

**មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបានថ្លែងការណ៍តបថា:** ខុនដូជាទ្រព្យសម្បត្តិរួម ព្រោះពួកគាត់រស់នៅជាមួយគ្នា ជាអនីតិសង្វាសតាំងពីឆ្នាំ២០១១ មកម្លេះ ប្រាក់ខែដើមចោទបង់ខុនដូ និងប្រាក់ខែចុងចម្លើយសម្រាប់ចាយវាយប្រចាំថ្ងៃ ដូចនេះស្នើសុំបែងចែកទ្រព្យ ខុនដូ និងសុំឲ្យដើមចោទដាក់ភស្តុតាងជាកិច្ចសន្យាទិញលក់ និងតារាងបង់រំលោះមកតុលាការ។

**១-៤-នីតិវិធីពិនិត្យភស្តុតាង**

-ឯកសារពាក់ព័ន្ធមួយចំនួន។

-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨។

-សេចក្តីថ្លែងការណ៍របស់មេធាវី [redacted] ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០២០។

-សេចក្តីថ្លែងការណ៍របស់មេធាវី [redacted] ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ ។

១-៥-ចំណុចវិវាទ: ដើមចោទស្នើសុំលែងលះតែចុងចម្លើយមិនព្រម។

## ២-សំអាងហេតុ

ឆ្លងកាត់តាមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយៈ

២-១-តាមសំបុត្រអាពាហ៍ពិពាហ៍លេខ: ០៥៥ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប បញ្ជាក់ឲ្យឃើញថា ដើមចោទ និងចុងចម្លើយ មានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

២-២-តាមសេចក្តីថ្លែងការណ៍របស់គូភាគីឃើញថា: ភាគីដើមចោទមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។ ប៉ុន្តែភាគីចុងចម្លើយមិនយល់ព្រមក្នុងការរំលាយទំនាក់ទំនងអាពាហ៍នេះទេ។ អាពាហ៍ពិពាហ៍មួយ កើតឡើង ដោយការស្ម័គ្រចិត្តរបស់គូភាគី តែនេះ ដើមចោទបានលើកឡើងថាខ្លួន អស់មនោសញ្ចេតនា ក្នុងការរស់នៅជាមួយចុងចម្លើយ ហើយការរស់នៅមានការឈ្លោះប្រកែក គ្នា ដូចនេះដើម្បីកុំអោយមានបញ្ហា ក៏ដូចជាផ្តល់សេរីភាពអោយភាគី ទៅថ្ងៃក្រោយ គប្បីតុលាការសម្រេចតាមការស្នើសុំរបស់ដើមចោទ។

២-៣-តាមការលើកឡើងរបស់ដើមចោទ និង ចុងចម្លើយ ក៏ដូចជាសេចក្តីថ្លែងការណ៍មេធាវី របស់គូភាគី ឃើញថា ភាគីទាំងពីរ បានរស់នៅបែកគ្នាជាបន្តបន្ទាប់ តាំងពីដើមខែសីហា ឆ្នាំ២០១៩ អស់រយៈពេលជាង១ឆ្នាំ នេះជាមូលហេតុនៃការលែងលះគ្នា ដែលអាចអោយតុលាការលើកយកមកពិចារណាបាន។



Scanned with CamScanner

២-៤-ចំពោះទ្រព្យសម្បត្តិរួម ដើមចោទអះអាងថា គ្មានទ្រព្យសម្បត្តិរួមទេ តែចុងចម្លើយអះអាងថាមាន ខុនដូ ០១កន្លែង មានទំហំ ៤១ម៉ែត្រការ៉េ ស្ថិតនៅជាន់ទី១៦ នៅលើផ្លូវ៣១៣ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ខ្សែករមាស ០១ខ្សែ ចិញ្ចៀនផ្កាទីន ០១វង់ និងក្រវិលពេជ្រ ០១គូរ ឃើញថា ចុងចម្លើយនៅតំណាក់កាលត្រៀម បានទាមទារបែងចែកចំណែក តែនៅក្នុងពេលទាញហេតុផលដោយផ្ទាល់មាត់បានដាក់បណ្ដឹងតប ដោយពុំបានប្ដឹងទាមទារ បែងចែកទ្រព្យសម្បត្តិរួមទេ ដោយខ្លួនសុំតែត្រូវគ្នាវិញជាមួយចុងចម្លើយតែប៉ុណ្ណោះ ហើយម្យ៉ាងវិញទៀតចុងចម្លើយពុំមានភស្តុតាងបញ្ជាក់ពីកម្មសិទ្ធិដាក់ជូនតុលាការទេ ដូចនេះគប្បីមិនតុលាការពិចារណា។

២-៥-ដោយដើមចោទយល់ព្រមទទួលបន្ទុក នូវប្រាក់ប្រដាប់ក្ដី ដូចនេះគប្បីតុលាការ សម្រេចតាមឆន្ទៈរបស់ដើមចោទដោយស្របតាមមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ៣-សេចក្ដីសម្រេចបញ្ចប់

១-ទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយឲ្យដើមចោទឈ្មោះ [redacted] រីះលែងលះពីចុងចម្លើយឈ្មោះ [redacted] សុធារី ចាប់ពីពេលសាលក្រមនេះចូលស្ថាពរ។

២-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃច័ន្ទ ១២រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ពស ២៥៦៤

សៀមរាប ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]